00655289

E9/16

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី សុំពន្យារពេលដាក់បញ្ជីឯកសារ និងភស្តុតាង**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> | <u>ផ្ញើជូន៖</u> |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូរ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

**ឯកសារដែលបានទទួល**
**DOCUMENT RECEIVED/DOCUMENT REÇU**
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 21 / 03 / 2011
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះ សូមស្នើសុំពន្យាពេលវេលាកំណត់ដាក់បញ្ជីឯកសារ និងភស្តុតាង។ សំណើនេះ មានលក្ខណៈចាំបាច់ព្រោះដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (“ដីកាបង្គាប់ស្តីពីការរៀបចំសវនាការ[1]”) តម្រូវឲ្យភាគីដាក់បញ្ជីទាំងនេះត្រឹមថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០១១ ប៉ុន្តែការដាក់កំហិតពេលកំណត់បែបនេះនឹងរំលោភដល់សិទ្ធិរបស់លោក អៀង សារី ដែលគេសន្មត់ទុកជាមុនថាជាជនគ្មានទោស និងសិទ្ធិរបស់គាត់ក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមការពារក្តីរបស់គាត់។ មេធាវីការពារក្តីបានធ្វើរួចទៅហើយនូវធ្វើសំណើស្រដៀងគ្នានេះ[2] ប៉ុន្តែមិនទាន់មានសេចក្តីសម្រេចណាមួយពីអង្គជំនុំជម្រះសាលាដំបូងទៅលើបញ្ហានេះនៅឡើយទេទោះបីជាពេលវេលាកំណត់នៃការដាក់បញ្ជីឯកសារ និងភស្តុតាងបានខិតកាន់តែជិតក៏ដោយ។ មេធាវីការពារក្តីសូមស្នើសុំការអនុញ្ញាតដាក់បញ្ជីទាំងនេះបន្ទាប់ពីការិយាល័យសហព្រះរាជអាជ្ញា (កសព) និងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញបញ្ជីរបស់ពួកគាត់ ។ ជាជម្រើសមួយផ្សេងទៀត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង សម្រេចមិនធ្វើតាមដំណើរការដែលដឹកនាំដោយភាគីដូចអ្វីដែលមេធាវីការពារក្តី[3] និង កសព[4] បានលើកឡើងទេនោះ មេធាវីការពារក្តី សូមស្នើដាក់បញ្ជីឯកសារ និងភស្តុតាងរបស់ខ្លួនក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់ទាក់ទងនឹងរចនាសម្ព័ន្ធនៃការជំនុំជម្រះក្តី និងដីកាសម្រេចលើប្រធានបទដែលនឹងត្រូវលើកយកមកដោះស្រាយ។

## I ច្បាប់ជាធរមាន

---

[1] *ករណី នួន ជា*, សំណុំរឿង ០០២-១៩-០៩-២០០៧-អវតក-អជសង, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១, ឯកសារ E9, ERN: 00635754-00635759។

[2] សូមមើល *ករណី អៀង សារី*, សំណុំរឿង ០០២-១៩-០៩-២០០៧-អវតក-អជសង, ពាក្យសុំរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបើកការជំនុំជម្រះក្នុងសំណុំរឿង០០២ ដោយអនុវត្តតាមនីតិវិធី និងសំណើដែលបានកែប្រែដើម្បីផ្អាកជាបន្ទាន់នូវដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E9/3, ERN: 00641756-00641760។

[3] ដូចជើងទំព័រខាងលើ។

[4] សូមមើល *ករណី នួន ជា*, សំណុំរឿង ០០២-១៩-០៩-២០០៧-អវតក-អជសង, បញ្ជីឈ្មោះ អ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់ ទី១, ទី២, ទី៣,ទី៤ និងទី ៥, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១, ឯកសារ E9/4.2, ERN: 00640732-00640736, កថាខណ្ឌទី១៥ ដល់២០។

### ក. ការសន្មត់ទុកជាមុនថាគ្មានទោស និងបន្ទុកភស្តុតាង

១. វិធាន៨៧ (១) នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា៖"សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។

២. មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ មាត្រា៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ចែងស្រដៀងគ្នាដែរថា៖ "ជនជាប់ចោទត្រូវចាត់ទុកជាមនុស្សឥតទោសដរាបណាតុលាមិនទាន់កាត់ទោសជាស្ថាពរ"។

៣. មាត្រា២១ (១) (ឃ) នៃវិធានផ្ទៃក្នុងបានចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោសដរាបណាពិរុទ្ធភាពរបស់គេមិនទាន់បានរកឃើញ"។

៤. មាត្រា១៤ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ចែងថា៖ "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់"។

៥. មាត្រា១១ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("UDHR") ចែងថា៖ "ជនណាដែលជាប់ចោទពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការសន្មត់ជាមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់គាត់ត្រូវបានកំណត់ស្របតាមច្បាប់ ក្នុងសវនាការជាសាធារណៈដែលជននោះមានការធានាទាំងអស់ដែលចាំបាច់ដើម្បីការពារក្តីរបស់គាត់"។

### ខ. ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីការពារក្តី

៦. មាត្រា១៣(១) នៃកិច្ចព្រមព្រៀង ចែងថា៖

> សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃរ៍រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង <u>សិទ្ធិមានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បី</u>

ត្រៀមរៀបចំការការពារខ្លួន សិទ្ធិទទួលបាននូវមេធាវីប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យសាក្សីដាក់បន្ទុក[5]។

៧. មាត្រា៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ចែងថា៖ "ក្នុងការចោទប្រកាន់មកលើខ្លួនជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាអប្បរមា និងស្មើៗគ្នាស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ...ខ)មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន...[6]" ។

៨. មាត្រា១៤ (៣) នៃ ចែងថា៖ "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បរមាដោយស្មើគ្នាយ៉ាងពេញលេញ... ខ) ត្រូវមានពេលវេលានិងសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន..."។

៩. មាត្រា១១ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("UDHR") ចែងថា៖ "ជនណាដែលជាប់ចោទពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការសន្មត់ជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់គាត់ត្រូវបានកំណត់ ស្របតាមច្បាប់ក្នុងសវនាការជាសាធារណៈដែលជននោះមានការធានាទាំងអស់ដែលចាំបាច់ដើម្បីការពារក្តីរបស់គាត់"។

## II. **សំណើ**

**ក. ការពន្យាពេលកំណត់ គឺចាំបាច់ដើម្បីការពារសិទ្ធិរបស់លោក អៀង សារី ដែលត្រូវសន្មត់ទុកជា មុនថាជាជនឥតទោស។**

១០. អង្គជំនុំជម្រះសាលាដំបូង ត្រូវតែអនុញ្ញាតឲ្យមានការពន្យាពេលវេលាកំណត់ដាក់បញ្ជីឯកសារ និងភស្តុតាងដូចដែលបានចែងក្នុងដីកាបង្គាប់របស់ខ្លួនដើម្បីការពារសិទ្ធិលោក អៀង សារី ដែលត្រូវបានគេសន្មត់ទុកជាមុនថាគ្មានទោស។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ[7]។ លោក អៀង សារី មិនត្រូវបានតម្រូវឲ្យបង្ហាញពីភាពគ្មានពិរុទ្ធរបស់គាត់ឡើយ *ព្រោះគាត់បានទទួលនូវការសន្មត់ទុកជាមុនថាគ្មានទោសរួចទៅហើយ* ប៉ុន្តែការតម្រូវឲ្យគាត់បង្ហាញពីបញ្ជីភស្តុតាងទាំងអស់ ដែលគាត់មានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

---

[5] គួសបញ្ជាក់បន្ថែម។

[6] គួសបញ្ជាក់បន្ថែម។

[7] សូមមើលវិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

មុនឯកសារដទៃទៀតដែលគេដាក់ប្រឆាំងរូបគាត់នៅពេលសវនាការ គឺធ្វើផ្ទុយនឹងបន្ទុកភស្តុតាង និងការសន្មត់ទុកជាមុនថាគាត់ជនជនឥតទោស។ វាហាក់បីដូចមានការសន្មត់ទុកជាមុនថាលោក អៀង សារី មានបញ្ហាដែលត្រូវឆ្លើយបំភ្លឺ។

១១. ដូចអ្វីដែលមេធាវីការពារក្តីធ្លាប់ពន្យល់រួចមកហើយថា ករណីស្រដៀងគ្នានេះអាចត្រូវបានគេទាញចេញពីតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") ព្រោះតុលាការទាំងពីរនេះជាប់ពាក់ព័ន្ធនិងការជំនុំជម្រះក្តីដែលមានទំហំ និងកម្រិតនៃភាពស្មុគស្មាញស្រដៀងគ្នានឹងការជំនុំជម្រះក្តីនៅ អវតក ផងដែរ ។ នៅតុលាការ ICC[8] និង ICTY[9] បន្ទុកនៃភស្តុតាង ក៏ស្ថិតនៅលើព្រះរាជអាជ្ញាផងដែរ ។ នៅតុលាការ ICC ប្រសិនបើចៅក្រមជំនុំជម្រះមិនបានផ្តល់ការណែនាំទេនោះ រដ្ឋអាជ្ញា និងមេធាវីការពារក្តីនឹងឯកភាពទៅលើលំដាប់លំដោយ និងរបៀបមួយដែលភស្តុតាងត្រូវដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូង[10]។ ក្នុងការអនុវត្តន៍ជាក់ស្តែង នៅតុលាការ ICC រដ្ឋអាជ្ញាត្រូវដាក់ឯកសាររបស់ពួកគេមុន បន្ទាប់មកបានមេធាវីការពារក្តីដាក់ឯកសាររបស់ខ្លួនតាមក្រោយ[11]។ ករណីនេះ នឹងទប់

---

[8] លក្ខន្តិកៈទីក្រុងរ៉ូម ត្រង់មាត្រា ៦៦ (២) ចែងថា៖ "ព្រះរាជអាជ្ញាមានបន្ទុកបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។

[9] "ដោយហេតុថាព្រះរាជអាជ្ញាត្រូវបានចងដោយកាតព្វកិច្ចក្នុងការបង្ហាញពីការចោទប្រកាន់ប្រឆាំងជនជាប់ចោទឱ្យហួសពីវិមតិ សង្ស័យ នោះជនជាប់ចោទ ត្រូវបានគេតម្រូវឱ្យបង្ហាញភស្តុតាងអំពីបញ្ហាដែលគាត់ប្រហែលជានឹងលើកឡើងទាក់ទងនឹងគុណភាពនៃភរនីយភាព"។ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Delalić et al.*, IT-96-21-T, សាលក្រម, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៨, កថាខណ្ឌទី៦០៣។

[10] វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICC, ថ្ងៃទី៣ដល់ទី១០ ខែកញ្ញា ឆ្នាំ២០០២ (វិធាននៃនីតិវិធី និងភស្តុតាងរបស់តុលាការ ICC ), វិធាន១៤០ (១)។

[11] សូមមើល ឧទាហរណ៍ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Katanga & Ngudjolo Chui*, ICC-PIDS-CIS-DRC2-01-001/09 , ព័ត៌មានស្តីពីសវនា, សំណួរនិងចម្លើយ, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩៖ "នៅក្នុងសវនាការ ការិយាល័យរដ្ឋអាជ្ញា នឹងបង្ហាញភស្តុតាងទាំងអស់ដោយខ្លួនឯងដោយដាក់ឯកសារជាច្រើនដែលខ្លួនបានចងក្រងក្នុងសំណុំរឿង និងសំរង់សោទស្សន៍ឱ្យចៅក្រមពិចារណា ។ ការិយាល័យព្រះរាជអាជ្ញា ក៏នឹងកោះហៅសាក្សីចំនួន២៦រូប រួមទាំងសាក្សីជំនាញមួយរូបផងដែរ។ ដូច្នេះមេធាវីការពារក្តីនឹងមានឱកាសសួរបដិសាក្សីដាក់បន្ទុកទាំងនោះ...បន្ទាប់ពីការសន្និដ្ឋានលើករណីចោទប្រកាន់នេះ ប្រហែលជាក្នុងរយៈពេល២ ឬ៣ ខែ ក្រុមមេធាវីការពារក្តី នឹងបង្ហាញពីភស្តុតាងដោះបន្ទុកដែលពួកគេមាន ហើយពួកគេនឹងកោះហៅសាក្សីជាច្រើនដើម្បីគាំទ្រភស្តុតាងដោះបន្ទុកនោះ។ សាក្សីទាំងនេះនឹងត្រូវចោទសួរដោយមេធាវីការពារក្តី និង ដោយមេធាវីដាក់បន្ទុក" ។

ស្កាត់កុំឱ្យបន្ទុកបង្ហាញភស្តុតាងរបស់រដ្ឋអាជ្ញាត្រូវបានគេជំនួស[12]។ នៅតុលាការ ICTY ដោយសារតែរដ្ឋអាជ្ញាជាប់បន្ទុកបង្ហាញភស្តុតាង រដ្ឋអាជ្ញាត្រូវតែបង្ហាញឯកសាររបស់ខ្លួនមុន បន្ទាប់មកបានមេធាវីការពារក្តីបង្ហាញឯកសាររបស់ខ្លួនតាមក្រោយ[13]។ ករណីស្រដៀងគ្នានេះ ក៏អាចត្រូវបានគេទាញចេញពីនីតិវិធីរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ("STL") ផងដែរ។ តុលាការ STL បានអនុវត្តច្បាប់ជាតិ[14] និងមានវិធាននៃនីតិវិធីរបស់ខ្លួនផ្ទាល់ (*sui generis*)[15] ។ ប្រព័ន្ធច្បាប់របស់ប្រទេសលីបង់ គឺយកលំនាំតាមប្រព័ន្ធច្បាប់បារាំង[16]។ នៅតុលាការ STL បន្ទុកភស្តុតាងក៏ស្ថិតនៅលើរដ្ឋអាជ្ញាផងដែរ[17]។ នៅទីនោះ "ដើម្បីផលប្រយោជន៍យុត្តិធម៌" រដ្ឋអាជ្ញាបានបង្ហាញឯកសាររបស់ខ្លួនមុន បន្ទាប់មកបានជនរងគ្រោះដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបង្ហាញពីឯកសាររបស់គេតាមក្រោម ហើយមេធាវីការពារក្តីបង្ហាញឯកសាររបស់ខ្លួនក្រោយគេ

[12] មាត្រា៦៧ (១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ចែងថាជនជាប់ចោទ ៖ "មិនបានដាក់លើខ្លួននូវការបដិសេធបន្ទុកនៃភស្តុតាង ឬបន្ទុកនៃការបដិសេធប្រឆាំងណាមួយឡើយ"។

[13] វិធាននៃនីតិវិធី និងភស្តុតាងនៅតុលាការ ICTY, វិធាន៨៥ (ក) ចែងថា៖ "ភាគីនីមួយមានសិទ្ធិកោះហៅសាក្សី និងបង្ហាញភស្តុតាង។ បើគ្មានការណែនាំផ្សេងពីនេះដោយអង្គជំនុំជម្រះដើម្បីជាប្រយោជន៍យុត្តិធម៌ទេនោះ ភស្តុតាងនៅសវនាការត្រូវតែបង្ហាញតាមលំដាប់លំដោយដូចតទៅនេះ (i) ភស្តុតាងចោទប្រកាន់ (ii) ភស្តុតាងការពារក្តី (iii) ភស្តុតាងបដិសេធរបស់ភាគីចោទប្រកាន់ (iv) ចម្លើយតបរបស់មេធាវីការពារក្តី (v) ភស្តុតាងដែលបង្គាប់ដោយអង្គជំនុំជម្រះស្របតាមវិធាន៩៨ និង (vi) ព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលអាចជួយអង្គជំនុំជម្រះក្នុងការសម្រេចដាក់ទោសឱ្យបានត្រឹមត្រូវប្រសិនបើជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធលើបទចោទមួយ ឬលើសពីមួយក្នុងដីកាចោទប្រកាន់"។

[14] លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ S/RES/1757 (2007) ("STL Statute"), ថ្ងៃទី៣០ ខែឧសភា ២០០៧ មាត្រា២។

[15] វិធាន នៃនីតិវិធី និងភស្តុតាង, តុលាការពិសេសសម្រាប់ប្រទេសលីបង់, STL/BD/2009/01/វិសោធនកម្មលើកទី៣ ("STL Rules of Procedure and Evidence"), ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០។

[16] Firas El Samad, ប្រព័ន្ធច្បាប់ និងការស្រាវជ្រាវរបស់ប្រទេសលីបង់ HAUSER GLOBAL LAW SCHOOL PROGRAM, NYU LAW, ខែវិច្ឆិកា/ធ្នូ ឆ្នាំ២០០៨, អាចរកមើលបាននៅ http://www.nyulawglobal.org/Globalex/Lebanon.htm#_2._Legal_system។

[17] លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសលីបង់, មាត្រា១៦ (៣) (ខ)។

បង្អស់[18] ។ ដោយសារតែនៅ អវតក បន្ទុកភស្តុតាងស្ថិតនៅលើ កសព ដូចនៅតុលាការ ICC តុលាការ ICTY តុលាការ ICTR និងតុលាការ STL ដែរនោះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែយកគំរូតាមវិធាននីតិវិធីដែលបានបង្កើតនៅស្ថាប័នទាំងនេះ ដើម្បីសម្រេចថា កសព និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញឯកសាររបស់ពួកគេមុនមេធាវីការពារក្តី។

១២. មេធាវីការពារក្តីមិនទាន់ដឹងនៅឡើយទេថាតើឯកសារ និងភស្តុតាងអ្វីខ្លះដែល កសព នឹងដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសវនាការ[19] ដូច្នេះក្នុងដំណាក់កាលនេះ មេធាវីការពារក្តីមិនអាចរៀបចំបញ្ជីឯកសារ និងភស្តុតាងរបស់ខ្លួនប្រឆាំងទៅនឹងឯកសារ និងភស្តុតាងរបស់ កសព បានឡើយ ។ នេះជាការពិតប្រសិនបើជាអង្គជំនុំជម្រះសាលាដំបូងសម្រេចមិនធ្វើការជំនុំជម្រះតាមបែបបទដែលដឹកនាំដោយភាគី ។

### ខ. ការពន្យារយៈពេលកំណត់ គឺចាំបាច់ដើម្បីការពារសិទ្ធិលោក អៀង សារី ក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់

១៣. ការពន្យារយៈពេលកំណត់ គឺចាំបាច់ដើម្បីការពារសិទ្ធិលោក អៀង សារី ក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីការពារខ្លួន ។ លោក អៀង សារី មានសិទ្ធិដាក់ឯកសារថ្មីដែលមិនទាន់មាននៅក្នុងសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង[20] ។ មេធាវីការពារក្តីចាំបាច់ត្រូវតែធ្វើការស៊ើបអង្កេតដោយខ្លួនឯង ដើម្បីឱ្យដឹងច្បាស់ថាតើខ្លួនត្រូវតែដាក់ឯកសារណាខ្លះដែលមិនទាន់មាននៅក្នុងសំណុំរឿងទៅកាន់អង្គជំនុំជម្រះសាលាដំបូង ឬយ៉ាងណា។ ប៉ុន្តែមេធាវីការពារក្តីត្រូវបានគេហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងឡើយខណៈពេលដែល កសចស

---

[18] វិធាន នៃនីតិវិធី និងភស្តុតាងនៅតុលាការពិសេសសម្រាប់ប្រទេសលីបង់, វិធាន១៤៦ (ខ) ចែងថា៖ "បើគ្មានការណែនាំផ្សេងពីនេះដោយអង្គជំនុំជម្រះដើម្បីជាប្រយោជន៍យុត្តិធម៌ទេនោះ ភស្តុតាងនៅសវនាការត្រូវតែបង្ហាញតាមលំដាប់លំដោយដូចតទៅនេះ (i) ភស្តុតាងរបស់ព្រះរាជអាជ្ញា (ii) ភស្តុតាងដែលបានបង្គាប់ដោយអង្គជំនុំជម្រះតាមការស្នើសុំរបស់ជនរងគ្រោះដែលបានចូលរួមក្នុងដំណើរការនីតិវិធី (iii) ភស្តុតាងការការពារក្តី (iv) ភស្តុតាងបដិសេធរបស់ព្រះរាជអាជ្ញា (vi) ភស្តុតាងបដិសេធតាមសំណើរបស់ជនរងគ្រោះដែលបានចូលរួមក្នុងដំណើរការនីតិវិធី (vi) ចម្លើយតបរបស់មេធាវីការពារក្តី"។

[19] បញ្ជីសម្ភារះរបស់ កសព ត្រូវបានបង្គាប់ឱ្យបង្ហាញក្នុងពេលវេលាដូចគ្នានឹងភាគីដទៃទៀតដែរ។ សូមមើលដីកាបង្គាប់ឱ្យភាគីដាក់សម្ភារះដើម្បីរៀបចំសវនាការ, កថាខណ្ឌទី១២។

[20] សូមមើលវិធាន៨០(៣) (ឃ), ដីកាបង្គាប់, កថាខណ្ឌទី១២ ដល់១៤។

ទទួលបានសំណុំរឿងនេះ[21]។ កសចស បានលើកឡើងថា៖ " នៅចំពោះមុខតុលាការនេះ អំណាចក្នុងការស៊ើបអង្កេត ត្រូវបានប្រគល់ទៅឱ្យតែសហចៅក្រមស៊ើបអង្កេតឯករាជ្យពីរនាក់ប៉ុណ្ណោះ គ្មានភាគីណាផ្សេងទៀតទេ ។ គ្មានបញ្ញត្តិណាអនុញ្ញាតឱ្យភាគីបើកកិច្ចស៊ើបសួរជំនួសសហចៅ-ក្រមស៊ើបអង្កេតឡើយ ហើយប្រព័ន្ធនីតិវិធីដទៃទៀតក៏មិនខុសគ្នាដែរ...ដូច្នេះសមត្ថភាពរបស់ភាគីក្នុងការធ្វើអន្តរាគមន៍ គឺត្រូវបានកម្រិតត្រឹមការស៊ើបសួរបឋមដែលចាំបាច់ដើម្បីអនុវត្តឱ្យមានប្រសិទ្ធិភាពនូវសិទ្ធិស្នើសុំកិច្ចស៊ើបសួរ[22]"។ ក្រោយមកទៀត កសចស បានបញ្ជាក់ពីការហាមឃាត់របស់ខ្លួនមិនឱ្យភាគីធ្វើការស៊ើបអង្កេតដោយខ្លួនឯង ដោយអះអាងនៅក្នុងការព្រមានដល់មេធាវីការពារក្តីថា៖ "តទៅនេះ សហចៅក្រមស៊ើបអង្កេត សូមព្រមានមេធាវីការពារក្តីលោក អៀង សារី តាមវិធាន៣៨ នៃវិធានផ្ទៃក្នុងថា ពួកគេត្រូវបានហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងឡើយ ហើយការរំលោភណាមួយចំពោះការហាមឃាត់នេះ អាចនាំឱ្យមានការអនុវត្តទោសប្រឆាំងពួកគេ[23]"។

១៤. នៅពេលដែល កសចស លែងទទួលបានសំណុំរឿងទេ ទើបបានជាមេធាវីការពារក្តីអាចព្យាយាមស្វែងរកឯកសារមួយចំនួន ដែលមិនមាននៅក្នុងសំណុំរឿងដើម្បីផ្តល់បញ្ជើឯកសារបែបនេះទៅឱ្យអង្គជំនុំជម្រះសាលាដំបូង ។ ធ្វើបែបនេះត្រូវការពេលវេលាច្រើន។ វាពិតជាចាំបាច់ដែលមេធាវីការពារក្តីត្រូវធ្វើការស៊ើបអង្កេតបែបនេះជាជាងពឹងផ្អែកលើតែឯកសារដែល កសចស ប្រមូលបាន ព្រោះវាមានភស្តុតាងដែលបញ្ជាក់ថាការស៊ើបអង្កេតរបស់ កសចស មានភាពលម្អៀងប្រឆាំងជនជាប់ចោទ ។ ឧទាហរណ៍សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde ត្រូវបានចោទប្រកាន់ដោយប្រធានអង្គភាពវិភាគ និងស៊ើបអង្កេតរបស់ កសចស ថាបានបង្ហាញពីចេតនារបស់គាត់ទៅកាន់អ្នកស៊ើបអង្កេតអន្តរជាតិថា **"គាត់ចង់ឱ្យ[ពួកគេ]ស្វែងរកភស្តុតាងដាក់បន្ទុកឱ្យ**

---

[21] សូមមើល ឧទាហរណ៍, *ករណី នួន ជា*, កសចស , ចម្លើយតបទៅកាន់លិខិតចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ទាក់ទងទៅនឹងការបើកការស៊ើបអង្កេតរបស់ពួកយើង, A110/I, ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨, ទំព័រទី២។ *ករណី អៀង សារី* សំណុំរឿង ០០២-១៩-០៩-២០០៧-អវតក-កសចស, ដីកាចេញការព្រមានស្របតាមវិធាន៣៨, ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១០, 367, ERN: 00478513-00478519, កថាខណ្ឌទី៩។

[22] *ករណី នួន ជា* សំណុំរឿង ០០២-១៩-០៩-២០០៧-អវតក-កសចស, អនុស្សារណៈរបស់ កសចស ផ្ញើទៅមេធាវីការពារក្តី, ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨, ទំព័រទី២ (គូសបញ្ជាក់បន្ថែម)។

[23] *ករណី អៀង សារី* សំណុំរឿង ០០២-១៩-០៩-២០០៧-អវតក-កសចស, ដីកាចេញការព្រមានស្របតាមវិធាន៣៨, ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១០, D367, ERN: 00478513-00478519 ("ដីកាព្រមាន"), កថាខណ្ឌទី៩។

00655297



**បានច្រើនជាងភស្តុតាងដោះបន្ទុក[24]"។**

១៥. សូម្បីតែឯកសារដែលមាននៅក្នុងសំណុំរឿង ក៏នឹងត្រូវការពេលវេលាច្រើនដើម្បីចងក្រងផងដែរ ហើយកិច្ចការដ៏ប្រុងប្រយ័ត្នមួយ មិនអាចត្រូវបានធ្វើឡើងមុនពេលវេលាកំណត់នៅពេលបច្ចុប្បន្ននេះបានឡើយ ។ មានឯកសាររាប់ម៉ឺនសន្លឹកដែលបានមកពីការស៊ើបអង្កេតរបស់ កសចស នៅក្នុងសំណុំរឿង ។ ទោះបីជាឯកសារខ្លះមានក្នុងសំណុំរឿងរាប់ឆ្នាំមកហើយក្តី ការបកប្រែឯកសារទាំងនោះទៅជាភាសាអង់គ្លេស និងភាសាខ្មែរ នៅតែបន្តដាក់បន្ថែមទៀតទៅក្នុងសំណុំរឿងរហូតទល់<u>ពេលបច្ចុប្បន្ននេះ</u>[25] ហើយមកទល់ពេលនេះ មិនមានការបកប្រែឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងឡើយ។ មេធាវីការពារក្តី មិនអាចពិនិត្យមើលឯកសារនីមួយៗតាមរយៈពេលកំណត់នៅបច្ចុប្បន្ននេះបានទេ។ ការស្នើឱ្យមេធាវីការពារក្តីផ្តល់បញ្ជីឯកសាររបស់ខ្លួនតាមពេលវេលាកំណត់ខាងលើនេះ នឹងរំលោភដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តីរបស់គាត់។

១៦. ការខ្វះមធ្យោបាយគ្រប់គ្រាន់ បានប៉ះពាល់ជាពិសេសដល់មេធាវីការពារក្តីព្រោះ កសព ត្រូវបានអនុញ្ញាតឱ្យបើកការស៊ើបអង្កេតបឋម មុនពេលដាក់ការសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួររបស់ខ្លួនទៅ កសចស ប៉ុន្តែ មេធាវីការពារក្តី ត្រូវបានគេហាមឃាត់មិនឱ្យបើកការស៊ើបអង្កេតបឋមលើសំណុំរឿង០០២ឡើយ។ កសព ក៏បានបើកការស៊ើបអង្កេតបឋមក្នុងសំណុំរឿង ០០១ ហើយត្រូវបានអនុញ្ញាតឱ្យបើកការស៊ើបអង្កេតលើរណីបន្ថែមទៀត ដែលមានផ្នែកខ្លះជាន់គ្នានឹងសំណុំរឿង០០២។ ជាងនេះទៅទៀតនៅពេលនេះ កសព ស្ថិតក្នុងស្ថានភាពមួយប្រសើរជាងមេធាវីការពារក្តីក្នុងការផ្តល់សម្ភារៈដែលបានស្នើសុំ ព្រោះ កសព គឺជាភាគីមួយក្នុងសំណុំរឿង០០១ ដូច្នេះហើយ កសព មានពេលវេលាច្រើនជាងមេធាវីការពារក្តីដើម្បីចងក្រងឯកសារដែលខ្លួនជឿថា

---

[24] សូមមើល *ករណី អៀង សារី* សំណុំរឿង ០០២-០៩-១០-២០០៩-អវតក-អបជ (១), បណ្តឹងរបស់លោក អៀង សារី សុំប្តឹងជំទាស់និងដកចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde និងសំណើសុំឱ្យមានសវនាការជាសាធារណៈ, ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ ERN: 00386956-00386968, ឧបសម្ព័ន្ធ ក, ទំព័រទី១។

[25] ឧទាហរណ៍, មេធាវីការពារក្តីត្រូវបានគេជូនដំណឹងកាលពីថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១១ ថាការបកប្រែឯកសារ D56-D0c.133, D366/7.1.50, D166/168.1, D166/170.1, IS 5.108, IS 19.3, IS 21.25, D222/1.18, D199/26.2.25, និង D200/2.13 ទៅជាភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលបន្ថែមទៅក្នុងសំណុំរឿង។ មេធាវីការពារក្តីមិនអាចពិនិត្យមើលឯកសារទាំងនេះឡើយ។

00655298



E9/16

អាចគាំទ្រដល់រឿងក្តីរបស់ខ្លួន។ កសព ក៏បានអនុវត្ត កាតព្វកិច្ចស្រដៀងគ្នានេះក្នុងសំណុំរឿង០០១ ដែលជាន់គ្នានឹងសំណុំរឿង០០២ ។ ដូច្នេះវានឹងមិនរំលោភដល់សមភាពនៃការតតាំងក្តីឡើយដែលតម្រូវឱ្យ កសព ផ្តល់នូវបញ្ជីឯកសារដែលបានស្នើសុំត្រឹមពេលកំណត់ដើម ហើយផ្តល់ការពន្យាពេលឱ្យមេធាវីការពារក្តីក្នុងការបង្ហាញឯកសាររបស់ខ្លួន។

**ដូច្នេះ** អាស្រ័យលើមូលហេតុដែលនបានលើកឡើងក្នុងសំណើនេះ មេធាវីការពារក្តី សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពន្យាពេលវេលាកំណត់ដល់មេធាវីការពារក្តីដើម្បីដាក់បញ្ជីឯកសារ និងភស្តុតាងរបស់ខ្លួន បន្ទាប់ពី កសព និងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បញ្ជីឯកសារ និងភស្តុតាងរបស់ពួកគេ ឬជាជម្រើសមួយផ្សេងទៀត មេធាវីការពារក្តីសុំពន្យាពេលដល់៦០ថ្ងៃគិតចាប់ពីថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាក់ទងនឹងរចនាសម្ព័ន្ធនៃការជំនុំជម្រះ និង លំដាប់លំដោយនៃប្រធានបទដែលនឹងត្រូវលើកយកមកពិភាក្សាដោះស្រាយ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

**ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**